# សង្ខេបនយោបាយការបរទេសចិនជាមួយកម្ពុជា

## ១.ប្រវត្តិទំនាក់ទំនងចិនជាមួយកម្ពុជា

ទំនាក់ទំនងកម្ពុជានិងចិនបានចាប់ផ្តើម និងចាក់ឫសយ៉ាងជ្រៅនៅក្នុងប្រវត្តិសាស្រ្តដ៏យូរលង់មិនតិចជាង ២០០០ឆ្នាំ បើគិតពីដំណើរទស្សនកិច្ចរបស់លោក កាំង ថៃ និងលោក ជូ យីង រាជទូតចិន ដែលបានទៅបំពេញទស្សនកិច្ចនៅកម្ពុជាក្នុងសម័យហ្វូណន។ ក្រោយមកទៀត ក៏មានទស្សនកិច្ចរបស់ លោក ជីវ តាក្វាន់ ទៅកាន់រាជធានីអង្គរ នេះគឺជាប្រវត្តិសាស្រ្តដ៏យូរលង់។ ក្នុងសម័យទំនើប ក្រោមការដឹកនាំរបស់ សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ និង លោកប្រធាន ម៉ៅ សេទុង កម្ពុជា-ចិន បានផ្សារភ្ជាប់ទំនាក់ទំនង ការទូតជាមួយគ្នា នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨ រៀងរហូតមក។[1] ប្រវត្តិសាស្រ្តបង្ហាញថា ខ្មែរ-ចិន មិនត្រឹមតែមានទំនាក់ទំនងខាងវប្បធម៌ អរិយធម៌ប៉ុណ្ណោះទេ ប្រទេសទាំងពីរនេះបានចងមេត្រីភាពគ្នាតាមរយៈជំនួញ និងបម្លាស់ប្តូរនៃជនជាតិផងដែរ។ ការធ្វើទំនាក់ទំនងជាមេត្រីនេះចាប់ផ្តើមតាំងពីព.ស២២៥ម្ល៉េះ។[2]

បើក្រឡេកថយក្រោយមើលព្រឹត្តិការណ៍ក្នុងតំបន់ និងរវាងចិន-អាម៉េរិក នៅពេលមានការឈ្លានពានរបស់សម្ព័ន្ធមិត្តអាម៉េរិកមានប្រទេសថៃ និងវៀតណាមខាងត្បូងនៅឆ្នាំ១៩៥៨ នៅខេត្តស្ទឹងត្រែង។ ការរំលោភលើព្រំដែនរបស់ប្រទេសកម្ពុជានេះ បានជំរុញឱ្យកម្ពុជាចាប់ផ្តើមពិនិត្យសារជាថ្មីនូវទំនាក់ទំនងរបស់ខ្លួនជាមួយក្រុងវ៉ាស៊ីនតោនដែលឈានទៅរកការឈប់ទទួលជំនួយសេដ្ឋកិច្ច និងយោធា។ នៅពេលនោះ សម្តេចព្រះនរោត្តម សីហនុ បានសុំឱ្យសហរដ្ឋអាម៉េរិករិកជួយធ្វើអន្តរាគមន៍ ប៉ុន្តែឯកអគ្គរដ្ឋទូតអាម៉េរិកថា សហរដ្ឋអាម៉េរិកហាមប្រាមមិនឱ្យប្រើគ្រឿងអាវុធអាម៉េរិកប្រឆាំងក្រុមសម្ព័ន្ធមិត្តអាម៉េរិកឡើយ គ្រឿងអាវុធអាម៉េរិកប្រើប្រាស់សម្រាប់ប្រឆាំងនឹងកម្លាំងកុម្មុយនីស្តតែម្យ៉ាង...។ មូលហេតុទាំងអស់នេះ ធ្វើឱ្យសម្តេច ព្រះនរោត្តម សីហនុ ចាប់ផ្តើមធ្វើទំនាក់ទំនងឡើងវិញជាមួយសាធារណរដ្ឋប្រជាមានិតចិន។[3]

នៅពេលដែលចិនបានប្រកាសទទួលស្គាល់ឯករាជ្យ អធិបតេយ្យ និងអព្យាក្រឹត្យរបស់ប្រទេសកម្ពុជានិងប្រទេសឡាវ គឺប្រទេសចិនប្រមើមើលថា នៅថ្ងៃអនាគតប្រទេសទាំងពីរនេះមាននយោបាយរបស់ខ្លួនរៀងខ្លួនមិនចំណុះ ឬត្រូវត្រួតត្រាដោយប្រទេសណាមួយឡើយ ជាពិសេសប្រទេសវៀតណាម។ ប្រទេសចិនដឹងថាប្រសិនប្រទេសកម្ពុជា និងប្រទេសឡាវក្លាយជាប្រទេសកុម្មុយនីស្តនោះប្រទេសទីមួយដែលចូលមកគ្រប់គ្រងកម្ពុជាមុនគេគឺប្រទេសជិតខាងនេះឯង ។ បើតាមប្រវត្តិសាស្រ្តក្នុងសម័យអាណានិគមកន្លងមក ទោះបីជាប្រទេសកម្ពុជា វៀតណាម ឡាវស្ថិតក្នុងតំបន់ឥណ្ឌូចិនតែមួយ ដែលបារាំងបានកំណត់ឱ្យហើយក៏ដោយ ក៏ប្រទេសវៀតណាមនៅតែមាន

ឥទ្ធិពលទៅលើប្រទេសទាំងពីរនេះដដែល ពីព្រោះមានព្រំប្រទល់ជាប់នឹងខ្លួន និងប្រទេសវៀតណាមជាជើងខ្លាំងមួយនៅសម័យនោះ ដែលពួកបារាំងពេញចិត្តជាងគេ។ នយោបាយរបស់ចិនដែលបានទទួលស្គាល់ឯករាជ្យ អធិបតេយ្យភាព និងអាព្យាក្រឹត្យភាពប្រទេសកម្ពុជា និង ប្រទេសឡាវ ហើយដាក់លក្ខខណ្ឌមួយទៅឱ្យប្រទេស

---

[1] សុន្ទរកថា សម្តេចតេជោ ហ៊ុន សែន ចូលរួមធ្វើជាអធិបតីក្នុងពិធីបើក វេទិកា ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងទេសចរណ៍កម្ពុជា-ចិន ឆ្នាំ២០១៧ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧។

[2] បណ្ឌិត សុខ ទូច , បណ្ឌិត ប៊ុន ធឿន៖ ទំនាក់ទំនងអន្តរជាតិ រវាងកម្ពុជា សហរដ្ឋអាម៉េរិក ចិន និងវៀតណាម ២០០៧ ទំព័រ១១៨

[3] -ដ- ទំព័រ១២៥ដល់ទំព័រ១២៦

កម្ពុជា និងឡាវហាមមិនឱ្យមានមូលដ្ឋានយោធារបស់កងទ័ពសហរដ្ឋអាម៉េរិកលើទឹកដីរបស់ខ្លួន។ ដូច្នេះយើងឃើញថា ប្រទេសចិនចំណេញនយោបាយ**បី** នៃនយោបាយការបរទេសរបស់ខ្លួនគឺ:[4]

**ទីមួយ** ប្រទេសចិនបានអាចកាត់បន្ថយនូវឥទ្ធិពលនៃអំណាចរបស់វៀតណាមដែលបានវាតទីទៅលើប្រទេសជិតខាងគឺកម្ពុជា និងប្រទេសឡាវ។ បើមិនដូច្នេះទេ ប្រទេសវៀតណាមនឹងកាន់កាប់លើទឹកដីនៃប្រទេសទាំងពីរនេះតាមរយៈចលនាកុម្មុយនីស្តរបស់ខ្លួនដែលមានស្រាប់( សល់ពីការតស៊ូបណ្តេញពួកបារាំងពីឥណ្ឌូចិន )នៅក្នុងប្រទេសទាំងពីរនេះ គឺពួកវៀតមិញ ។

**ទីពីរ** ប្រទេសកម្ពុជា និងប្រទេសឡាវ ដើម្បីទទួលបានការទទួលស្គាល់ឯករាជ្យរបស់ខ្លួនពីប្រទេសចិននោះលុះត្រាត្រាតែមានការតបស្នងទៅវិញដល់ប្រទេសចិន គឺត្រូវបំពេញលក្ខខណ្ឌ មិនត្រូវអនុវត្តឱ្យមានកងទ័ពអាម៉េរិកបោះទីតាំងមូលដ្ឋានយោធាលើទឹកដីរបស់ខ្លួនឡើយ ។ ដូច្នេះ ប្រទេសចិននឹងអាចទប់ស្កាត់ការសាយភាយធំៗនៃប្លុកសេរីដែលមានមហាអំណាចសហរដ្ឋអាម៉េរិកនៅក្នុងតំបន់ឥណ្ឌូចិន ក៏ដូចជាតំបន់អាស៊ីអាគ្នេយ៍ទាំងមូល ។

**ទីបី** ចំពោះការទាញយកផលប្រយោជន៍ទាំងពីរខាងលើ ចំពោះនយោបាយការបរទេសរបស់សាធារណរដ្ឋប្រជាមានិតចិននោះ គឺជាស្ពានមួយដើម្បីឆ្លងចាប់យកផលចំណេញផ្នែកនយោបាយខាងផ្លូវការទូតទៀត។ យុទ្ធសាស្រ្តរបស់ចិនមានរូបភាពខាងក្រៅហាក់ដូចជាធម្មតា គឺប្រទេសចិនជាប្រទេសមួយដែលស្រឡាញ់ និងគោរពឯករាជ្យ អធិបតេយ្យភាពរបស់ប្រទេសដទៃ ប៉ុន្តែរូបភាពខាងក្នុងវិញបង្កប់ទៅដោយមហិច្ឆិតានៃអំណាចដើម្បីពង្រីកឥទ្ធិពលរបស់ខ្លួនទៅវិញទេ។ នយោបាយការបរទេសរបស់ប្រទេសចិនដំបូងឡើយមានរូបរាងជាមិត្តភាពរវាងប្រទេសកម្ពុជា និងចិនដោយប្រទេសចិនបានផ្តល់ជំនួយ សេដ្ឋកិច្ច និងសម្ភារៈជា និងចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មផងដែរ ។

រហូតដល់ក្នុងឆ្នាំ១៩៩៣នៅចំពោះមុខរដ្ឋាភិបាលពីរបស់កម្ពុជា ចិនពីដំបូងបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សហ៊្វុនស៊ិនប៉ិច។ ប៉ុន្តែក្រោយមកនៅពេលដែលបក្សរាជានិយមហ៊្វុនស៊ិនប៉ិចចាប់ផ្តើមចុះខ្សោយ ក្រុងប៉េកាំងបានងាកទៅកសាងទំនាក់ទំនងល្អជាមួយគណបក្សប្រជាជនកម្ពុជាវិញម្តង។ នៅក្នុងខែកក្កដា ឆ្នាំ១៩៩៦ ចិនបានបញ្ជូនបក្សីស្លាបដែកមកទទួលលោក ហ៊ុន សែន ទៅធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសចិន។ បន្ទាប់ពីនោះមក ទំនាក់ទំនងកាន់តែប្រសើរឡើងរវាងប៉េកាំងនិងភ្នំពេញ បានស្តែងឲ្យឃើញកាន់តែច្បាស់តាមរយៈ ការផ្លាស់ប្តូរទស្សនកិច្ចជាញឹកញាប់រវាងប្រមុខដឹកនាំនិងមន្ត្រីជាន់ខ្ពស់នៃប្រទេសទាំងពីរ ក៏ដូចជាជំនួយរបស់ចិនដល់កម្ពុជា។[5]

## ២.នយោបាយការបរទេសចិនជាមួយកម្ពុជាបច្ចុប្បន្ន

នៅឆ្នាំ២០២០«ការកែទម្រង់ខាងក្នុង និងការបង្កើតមិត្តនៅក្រៅប្រទេស ដោយផ្អែកលើស្មារតីឯករាជ្យភាព» គឺជាចក្ខុវិស័យជាយុទ្ធសាស្រ្តដែលត្រូវបានបញ្ជាក់ដោយនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងការបង្កើតគោលនយោបាយ និងយុទ្ធសាស្រ្តការបរទេសរបស់កម្ពុជា។ នៅក្នុងបរិបទនេះលោកនាយករដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា កម្ពុ

---

[4] -ដ- ទំព័រ១៥០ដល់ទំព័រ១៥២

[5] អ៊ឹម រចនា៖ ចុះផ្សាយថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០៖ "កម្ពុជានិងចិន៖ ទំនាក់ទំនងចាស់វស្សាដែលផ្តល់ប្រយោជន៍ទាំងសងខាង" វិទ្យុបារាំង, www.rfi.fr/km/កម្ពុជា/20201012-កម្ពុជា-ចិន-ប្រវត្តិទំនាក់ទំនងការទូត ( accessed December 05, 2020 at 8:47pm )

ជាចាំបាច់ត្រូវបង្កើតមិត្តជាមួយបណ្ដាប្រទេសទាំងអស់ ប៉ុន្តែកម្ពុជានឹងមិនធ្វើសម្បទាន ឬប្រគល់អធិបតេយ្យភាព និងសន្តិសុខជាតិជាថ្នូរនឹងជំនួយបរទេស និង/ឬពាណិជ្ជកម្ម និងការវិនិយោគណាមួយឡើយ។ ទោះជាយ៉ាងណាក៏ដោយ មានប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិមួយចំនួន មិនបានទទួលស្គាល់ដំណោះស្រាយរបស់កម្ពុជា ក្នុងការការពារអធិបតេយ្យភាព និងឯករាជ្យភាពជាតិ និងការលើកកម្ពស់ផលប្រយោជន៍ជាតិរបស់ខ្លួនឡើយ។ ចិនគឺជាដៃគូពាណិជ្ជកម្ម និងការវិនិយោគបរទេសធំបំផុតនៅកម្ពុជា។ ការពង្រឹងសេដ្ឋកិច្ចជាមួយចិនឱ្យកាន់តែមានភាពស៊ីជម្រៅបានជួយឱ្យកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ យ៉ាងរឹងមាំជាមួយ នឹងអត្រាជាមធ្យមច្រើនជាង៧ភាគរយ ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ។ ទោះយ៉ាងណាក៏ដោយការពង្រឹងទំនាក់ទំនងទ្វេភាគីជាមួយចិនមិនមានន័យថា កម្ពុជាចាំបាច់ត្រូវសម្រុះសម្រួលឯករាជ្យភាព និងអធិបតេយ្យភាពរបស់ខ្លួនឡើយ។ ឯករាជ្យភាព និងការប្ដេជ្ញាចិត្តរបស់កម្ពុជាក្នុងនាមជារដ្ឋអធិបតេយ្យនៅតែមានដដែល។ ជំហរនយោបាយការបរទេសរបស់កម្ពុជាគឺគាំទ្រកម្ពុជា។ ការគាំទ្ររបស់កម្ពុជាចំពោះចិន និងប្រទេសជាមិត្តដទៃទៀតរបស់ខ្លួន ក្នុងការប្រយុទ្ធប្រឆាំងនឹងការផ្ទុះឡើងនៃមេរោគកូរ៉ូណាវីរុស គឺផ្អែកលើកាតព្វកិច្ចខាងសីលធម៌ និងជាអន្តរជាតិ។ សីលធម៌សង្គមរបស់កម្ពុជាគឺ « មិត្តពិតប្រាកដ គឺជាមិត្តដែលចេះជួយគ្នាក្នុងគ្រាលំបាក»។ ក្នុងកំឡុងពេលនៃការផ្ទុះឡើងដំបូង នៃវីរុសនេះនៅទីក្រុង Wuhan នៃប្រទេសចិន នាយករដ្ឋមន្ត្រី ហ៊ុន សែន បានទៅធ្វើទស្សនកិច្ច និងបានទៅសួរសុខទុក្ខលោកប្រធានាធិបតីចិន ស៊ី ជីនពីង នៅរដ្ឋធានីប៉េកាំង ខណៈដែលពិភពលោកទាំងមូលកំពុងប្រញ៉ាប់ប្រញ៉ាល់ ទៅយកប្រជាពលរដ្ឋរបស់ពួកគេ ចេញពីទីក្រុងវូហាន។ ចិនគោរពឯករាជ្យអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា ហើយកម្ពុជា គាំទ្រជានិច្ចនូវគោលនយោបាយចិនតែមួយ។ កម្ពុជាទទួលស្គាល់ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ថាជារដ្ឋាភិបាលស្របច្បាប់តែមួយគត់ ដែលតំណាងឱ្យចិនទាំងមូល រួមមានហុងកុង ម៉ាកាវ និងតៃវ៉ាន់។ កម្ពុជាចាត់ទុកទឹកដីទាំងបីជាតំបន់រដ្ឋបាលពិសេសរបស់ចិន។ កម្ពុជាប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ចំពោះគោលនយោបាយនេះនៅគ្រប់កាលៈទេសៈ។[6]

## ២.១.កិច្ចសហប្រតិបត្តិការទ្វេភាគី

សុន្ទរកថាសម្ដេចបានថ្លែងក្នុងវេទិកាសកលស្ដីពី ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រឆ្នាំ ២០១៥ ក្នុងឱកាសខួបលើកទី២៣នៃទិវាលុបបំបាត់ភាពក្រីក្រអន្តរជាតិ ស្ដីពី ការអភិវឌ្ឍរួម តាមរយៈកិច្ចប្រឹងប្រែងរួម ក្នុង ការលុបបំបាត់ភាពក្រីក្រ នៅក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិនសម្ដេចបានលើកឡើងនៅវិធានការ៥ចំណុចដើម្បីបង្កើតនូវឱកាសឲ្យប្រជាពលរដ្ឋទាំងអស់ បានចូលរួមនៅក្នុងសកម្មភាពសង្គម-សេដ្ឋកិច្ច៖[7]

---

[6] Freshnewsasia៖ ចុះផ្សាយថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ៖ "គោលនយោបាយការបរទេសរបស់កម្ពុជា៖ មិត្តពិតប្រាកដ គឺជាមិត្តដែលចេះជួយគ្នាក្នុងគ្រាលំបាក" http://m.freshnewsasia.com/index.php/en/opinioneditorial/153241-2020-03-31-10-15-09.html (accessed January 27, 2021 at 7:29am)។

[7] http://km.cnv.org.kh/៖ ចុះផ្សាយថ្ងៃ១៦ ខែតុលា ឆ្នាំ២០១៥ ៖ "សុន្ទរកថា ថ្លែងក្នុងវេទិកាសកលស្ដីពី ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រឆ្នាំ ២០១៥ ក្នុងឱកាសខួបលើកទី២៣នៃទិវាលុបបំបាត់ភាពក្រីក្រអន្តរជាតិ ស្ដីពី ការអភិវឌ្ឍរួម តាមរយៈកិច្ចប្រឹងប្រែងរួម ក្នុង ការលុបបំបាត់ភាពក្រីក្រ, ក្រុងប៉េកាំង, សាធារណរដ្ឋប្រជាមានិតចិន", km.cnv.org.kh/2015/សុន្ទរកថា-ថ្លែងក្នុងវេទ/ (accessed October 19, 2015 at 8:11pm)។

**ទី១.** ការខិតខំរក្សាឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង និងការជម្រុញផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចឆ្ពោះទៅរកវិស័យដែលមានផលិតភាពខ្ពស់ជាងមុន ពិសេសតាមរយៈការជម្រុញ ការអភិវឌ្ឍ សហគ្រាសខ្នាតតូច និងមធ្យមក្នុងស្រុក ការបន្តទាក់ទាញការវិនិយោគ និងបង្កើនការវិនិយោគលើហេដ្ឋា រចនាសម្ព័ន្ធរូបវន្ត ដើម្បីជួយពន្លឿនការតភ្ជាប់តំបន់ដាច់ស្រយាលជាមួយនឹងទីប្រជុំជន ព្រមទាំងជាមួយ ទីផ្សារ ក៏ដូចជាការតភ្ជាប់រវាងបណ្តាប្រទេសនានានៅក្នុងតំបន់។

**ទី២.** ដោយប្រជាជនក្រីក្រជាច្រើនប្រកបរបរកសិកម្ម ជាពិសេសក្នុងពេលបច្ចុប្បន្ន ខណៈដែលថ្លៃកសិផលកំពុងតែធ្លាក់ចុះទាប យើងត្រូវតែបន្តផ្តោតការយកចិត្តទុកដាក់ថែមទៀត ដល់ការវិនិយោគលើវិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ដូចជាប្រព័ន្ធស្រោចស្រព និងប្រព័ន្ធគ្រប់គ្រងទឹកជាដើម រួមជាមួយនឹងការបន្តផ្តល់កាន់តែប្រសើរឡើង នូវសេវាគាំទ្រ បច្ចេកវិទ្យាថ្មីៗ និងធាតុចូលផ្សេងទៀតក្នុងវិស័យនេះ ដើម្បីបង្កើនផលិតភាព ជម្រុញផលិតកម្ម និងជម្រុញការនាំចេញ។ បន្ថែមលើនេះ បញ្ហាគ្រោះធម្មជាតិធ្ងន់ធ្ងរ ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ ជាដើម ត្រូវបានព្យាករណ៍ថា នឹងបន្តការកើនឡើង ដោយសារតែការប្រែប្រួលអាកាសធាតុ។ ដូច្នេះ នាពេលអនាគត ការដោះស្រាយបញ្ហាសន្តិសុខស្បៀងនឹងក្លាយជាអាទិភាពកាន់តែសំខាន់ ពិសេសគឺការគ្រប់គ្រង និងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានពីការប្រែប្រួលអាកាសធាតុ និងការផ្សាំប្រព័ន្ធកសិកម្មទៅនឹងគ្រោះធម្មជាតិដ៏ធ្ងន់ធ្ងរ ដែលអាចកើតមានឡើងកាន់តែញឹកញាប់ជាងមុន។

**ទី៣.** ការពន្លឿនការអនុវត្តគោលនយោបាយសេរីភាវូបនីយកម្មពាណិជ្ជកម្ម ពិសេសតាមរយៈការធ្វើឲ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្ម ការផ្តល់ការអនុគ្រោះដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងការកាត់បន្ថយរបាំងពាណិជ្ជកម្ម ដើម្បីធ្វើពិពិធកម្មផលិតផលនាំចេញ និងពិពិធកម្មទីផ្សារក្នុងតំបន់ និងពិភពលោក។

**ទី៤.** ការលើកកម្ពស់គុណភាពនៃការអប់រំ និងការបណ្តុះបណ្តាលជំនាញដែលបង្កើតតម្លៃបន្ថែមខ្ពស់ ជា អាទិ៍ ជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវិស្វកម្ម ក៏ដូចជាការលើកស្ទួយប្រភេទអាជីពការងារ និងការ ពង្រឹងការអប់រំ បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ គួបផ្សំជាមួយនឹងការពង្រឹងកម្មវិធីគាំពារសង្គម សំខាន់ៗ។

**ទី៥.** ការលើកកម្ពស់បរិយាប័ន្ននៃវិស័យហិរញ្ញវត្ថុ និងការផ្តល់ភាពងាយស្រួលចំពោះការទទួលបាន ប្រភពហិរញ្ញប្បទាន ដើម្បីផ្តល់ឱកាសឲ្យប្រជាជនទាំងអស់មានលទ្ធភាពទទួលបាននូវសេវាហិរញ្ញវត្ថុ។

នៅឆ្នាំ២០២០ប្រធានាធិបតី ស៊ី ជីនភីង បានមានប្រសាសន៍ថា ការរួមគ្នាប្រយុទ្ធប្រឆាំងនឹងជំងឺ កូវីដ១៩ បង្ហាញឲ្យឃើញនូវសហ គមន៍ចិន-កម្ពុជា រួមអនាគតដែលមិនអាចបំបែកបាន។ ប្រធានាធិបតី ស៊ី ក្នុងនាមជាអគ្គលេខាធិការគណៈកម្មាធិការ មជ្ឈិមបក្សកុម្មុយនិស្តចិនផងដែរ បានធ្វើការកត់សម្គាល់នៅក្នុងសារលិខិតផ្ញើជូន (សម្តេចតេជោ) ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាច និងជានាយករដ្ឋមន្ត្រីនៃកម្ពុជា។ ប្រធានាធិបតីចិន ស៊ី ជីនភីង បានថ្លែងអំណរគុណចំពោះ (សម្តេចតេជោ) ហ៊ុន សែន ដែលបានផ្ញើលិខិតអបអរខួបលើកទី៩៩ នៃការបង្កើតគណៈកម្មាធិការមជ្ឈិម បក្សកុម្មុយនិស្តចិន នាពេលកន្លងទៅ ដែលបានបង្ហាញពីបំណងប្រាថ្នា និងទស្សនៈរបស់គណបក្សប្រជាជនកម្ពុជា ស្តីពីការធ្វើអោយកាន់តែស៊ីជំរៅទំនាក់ទំនងរវាងគណបក្ស និងប្រទេសទាំងពីរ ការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការដទៃទៀតរវាងបក្ស និងលើកកម្ពស់ការកសាងសហគមន៍ចិន-កម្ពុជា មានអនាគតរួមគ្នា ដើម្បីជាប្រយោជន៍ដល់ប្រទេស និងប្រជាជនទាំងពីរ។ ចិនថាទំនាក់ទំនងចិននិងកម្ពុជា ជាអ្នកជិតខាង និងដៃគូល្អ ដែលជួយ និងគាំទ្រគ្នាទៅវិញទៅមក ចាប់តាំងពីការចាប់ផ្តើម នៃការរីករាលដាលនៃជំងឺ

កូវីដ១៩ ភាគីទាំងពីរបានរក្សាការគាំទ្រគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ហើយសំរេចបាននូវវឌ្ឍនភាពដ៏សំខាន់ ក្នុងការប្រយុទ្ធរួមគ្នាប្រឆាំងនឹងជំងឺនេះ។ ចិនយល់ថាការបំពេញទស្សនកិច្ចរបស់(សម្តេចតេជោ) ហ៊ុន សែន ទៅកាន់ប្រទេសចិន នៅពេលដែលស្ថានភាពរាតត្បាតនៃជំងឺនៅមានសភាពធ្ងន់ធ្ងរនោះ បានបន្សល់ទុកនូវចំណាប់អារម្មណ៍យ៉ាងជ្រាលជ្រៅ សំរាប់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន រដ្ឋាភិបាល និងប្រជាជនចិន ព្រមទាំងខ្លួនលោកផងដែរ។ ចិនគាំទ្រយ៉ាងមុតមាំដល់ប្រទេសកម្ពុជា ក្នុងការដើរលើមាគ៌ាអភិវឌ្ឍន៍មួយ សមស្របទៅនឹងលក្ខខណ្ឌជាតិរបស់ខ្លួន ហើយជឿជាក់ថា ក្រោមការដឹកនាំរបស់ (សម្តេចតេជោ) ហ៊ុន សែន កម្ពុជានឹងពិតជាសម្រេចបាននូវសមិទ្ធផលថ្មីៗ ក្នុងបុព្វហេតុកសាងជាតិ និងចូលរួមចំណែកវិជ្ជមានក្នុងការលើកកម្ពស់ស្ថេរភាព និងការអភិវឌ្ឍក្នុងតំបន់។[8]

## ២.២.កិច្ចព្រមព្រៀងសំខាន់កម្ពុជា-ចិន

នៅឆ្នាំ២០១៦ កិច្ចព្រមព្រៀងចំនួន៣១ត្រូវបានចុះហត្ថលេខានៅចំពោះមុខសម្តេចតេជោហ៊ុន សែននិងលោកស៊ីជីនភីង។ ពិធីចុះហត្ថលេខាលើព្រមព្រៀង និងពិធីសារចំនួន៣១នៅឯវិមានសន្តិភាពកិច្ចព្រមព្រៀង និងពិធីសារទាំងនោះរួមមាន៖[9]

ទី១៖ កិច្ចព្រមព្រៀងស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងដំណាក់កាលថ្មី

ទី២៖ អនុស្សារណៈយោគយល់គ្នា ស្តីពីការរៀបចំចំណុចនៃផែនការកិច្ច សហប្រតិបត្តិការទ្វេភាគី ដើម្បីរួមគ្នាបង្កើត កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចផ្លូវសូត្រ និងកិច្ចសហប្រតិបត្តិការផ្លូវសូត្រសមុទ្រ សតវត្សទី២១

ទី៣៖ កិច្ចព្រមព្រៀងស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសស្តីពី ការផ្តល់ហិរញ្ញប្បទានឥតសំណងចំនួន ១,២០០លានយ័នចិន

ទី៤៖ អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការសមុទ្រ

ទី៥៖ កិច្ចព្រមព្រៀងស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យវិទ្យុ និងទូរទស្សន៍

ទី៦៖ អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យអធិការកិច្ច

ទី៧៖ អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកម្មវិធីផ្លាស់ប្តូរទស្សនកិច្ចអ្នកវិទ្យាសាស្ត្រ

ទី៨៖ កិច្ចព្រមព្រៀងស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា

ទី៩៖ លិខិតប្តូរសារស្តីពីគម្រោង សាងសង់អាគារពេទ្យមិត្តភាពកម្ពុជា-ចិន ទី១០៖ ពិធីសារស្តីពីការលុបឥណទានឥតការប្រាក់

---

[8] Xinhua, "Xi says joint COVID-19 fight shows China-Cambodia community with shared future unbreakable", xinhuanet, July 3, 2020, http://www.xinhuanet.com/english/2020-07/03/c_139186696.htm (accessed September 02, 2020 at 8:00pm)

[9] Cri ccfr៖ ចុះផ្សាយថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ៖ "កិច្ចព្រមព្រៀងចំនួន៣១ត្រូវបានចុះហត្ថលេខានៅចំពោះមុខសម្តេចតេជោហ៊ុន សែន និងលោកស៊ីជីនភីង" https://www.facebook.com/ccfr.cri/posts/686641171490733/ (accessed January 29, 2021 at 12:21pm)។

ទី១១៖ កិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការសន្យាផ្តល់ឥណទាន សម្បទានជាប្រាក់យ័នចិន សម្រាប់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រជំហានទី២

ទី១២៖ កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ជាឥណទានឥតការប្រាក់សម្រាប់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រវ៉ៃកូ ជំហានទី២

ទី១៣៖ កិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការសន្យាផ្តល់ឥណទាន ជាប្រាក់យ័ន ចិនសម្រាប់គម្រោងសាងសង់ផ្លូវជាតិលេខ៥១

ទី១៤៖ កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ជាឥណទានការប្រាក់សម្រាប់សាងសង់ផ្លូវជាតិលេខ៥១

ទី១៥៖ កិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការសន្យាផ្តល់ឥណទានសម្បទាន ជាប្រាក់យ័នចិន សម្រាប់គម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុងទី២

ទី១៦៖ អនុស្សារណៈនៃការយោគយល់គ្នា សម្រាប់សិក្សាប្លង់មេស្តីពីផែនការគម្រោង ធនធានទឹកនៅកម្ពុជា និងគម្រោងរៀបចំ និងគាំទ្រសម្ភារៈគម្រោង វិទ្យាស្ថានធន ធានទឹក

ទី១៧៖ លិខិតប្តូរសារស្តីពីប្រព្រឹត្តកម្ម មិនជាប់ពន្ធចំនួន៩៧ភាគរយ នៃមុខទំនិញសរុប

ទី១៨៖ អនុស្សារណៈនៃការយោគយល់ គ្នាស្តីពីការជំរុញគម្រោងកិច្ចសហប្រតិបត្តិការ វិនិយោគឧស្សាហកម្មគន្លឹះ

ទី១៩៖ អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីដំណើរការកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរ ព័ត៌មានចារកម្មពាក់ព័ន្ធលើវិស័យអនុវត្តច្បាប់សន្តិសុខផ្ទៃប្រទេស

ទី២០៖ កិច្ចព្រមព្រៀងស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស

ទី២១៖កិច្ចព្រមព្រៀងសម្បទានសម្រាប់ការអភិវឌ្ឍអាកាសយាន ដ្ឋានអន្តរជាតិ សៀម រាបអង្គរ

ទី២២៖ កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិន សម្រាប់គម្រោងអភិវឌ្ឍន៍ ប្រពន្ធធារាសាស្ត្រវ៉ៃកូ ជំហានទី២

ទី២៣៖ កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិន សម្រាប់គម្រោងសាងសង់ ផ្លូវជាតិលេខ៥១

ទី២៤៖ កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិន សម្រាប់គម្រោងសាងសង់ ផ្លូវក្រវ៉ាត់ក្រុងទី២

ទី២៥៖ កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់ដុល្លារអាម៉េរិក សម្រាប់គម្រោង សាងសង់ខ្សែបញ្ជូនអគ្គិសនីជនបទជំហានទី៥ និងទី៦

ទី២៦៖ កិច្ចសន្យាសាងសង់ផ្លូវជាតិលេខ១១ អ្នកលឿង ថ្នល់ទទឹង

ទី២៧៖ អនុស្សារណៈយោគយល់គ្នារវាងក្រុមហ៊ុន Green Trade កម្ពុជា និងក្រុមហ៊ុន COFCO ចិន ស្តីពីការនាំអង្ករ ២សែនតោន ទៅប្រទេសចិន

ទី២៨៖ កិច្ចសន្យាសាងសង់នៃគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០ KV ជំហានទី២

ទី២៩៖ អនុស្សារណៈយោគយល់គ្នាស្តីពីការវិនិយោគ និង អភិវឌ្ឍខ្សែបណ្តាញអគ្គិសនីជាតិ

ទី៣០៖ កិច្ចព្រមព្រៀងពិធីសារ សម្រាប់គម្រោងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម ៤៥០MV នៅក្រុងព្រះសីហនុ

ទី៣១៖ កិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចី ៤០០លានយ័ន។

## ២.៣.ការបរទេសចម្រុះពណ៌របស់កម្ពុជា

នៅថ្ងៃទី១ ខែកុម្ភ ឆ្នាំ២០២១ ក្នុងពិធីបើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង និងប្រកាសសម្ពោធដាក់ឱ្យដំណើរការផ្លូវការរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំការមន សម្តេចតេជោ ហ៊ុន សែនលើកឡើងយ៉ាងដូច្នេះថា៖ «ខ្ញុំក៏សូមអំពាវនាវចំពោះសហភាពអឺរ៉ុបដែរ បើមានលទ្ធភាពជួយដល់កម្ពុជា (វ៉ាក់សាំង) យើងខ្ញុំអរគុណ។ រាប់ទាំងលោកជំទាវអគ្គរដ្ឋទូតបារាំង ប្រាប់ទៅឯកឧត្តមប្រធានាធិបតីម៉ាក្រុងថា កម្ពុជាក៏ត្រូវការជំនួយដ៏សប្បុរសពីសាធារណរដ្ឋបារាំងដែរ។ កុំមើលឃើញថាកម្ពុជាត្រូវការតែចិននោះ ត្រូវការទាំងអស់ហ្នឹង។ កម្ពុជាមើលគ្រប់ជ្រុងទាំងអស់ បានសេចក្តីថាមើលជុំវិញខ្លួន មិនមែនមើលតែទិសណាមួយទេ។ ឥណ្ឌាមាននយោបាយសំឡឹងមកទិសខាងកើត បន្ទាប់មកជំនាន់នាយករដ្ឋមន្ត្រីមូឌី ប្រើពាក្យថា សកម្មភាពមកទិសខាងកើត។ ប្រធានាធិបតីកូរ៉េខាងត្បូង ម៉ូន ចេអ៊ីន ប្រើពាក្យថា សកម្មភាពមកទិសខាងត្បូង។ ឯសម្រាប់ខ្ញុំ សកម្មភាពជុំវិញខ្លួន មើលគ្រប់ទិស។ នេះជាគោលនយោបាយការបរទេសរបស់យើង»។[10]

## ២.៤.ទំនាក់ទំនងចិន-កម្ពុជាចន្លោះសហរដ្ឋអាម៉េរិក

១៨ឆ្នាំមុនកាសែតធំៗរបស់អាម៉េរិកធ្លាប់កុហកពិភពលោកថា «អ៊ីរ៉ាក់មានអាវុធប្រល័យលោក» ខណៈពេលកាសែតធំៗដដែលនោះបន្តកុហកពិភពលោកទៀតថា «កម្ពុជាមានមូលដ្ឋានទ័ពចិន»។ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៣ កងទ័ពអាម៉េរិក១៣០,០០០នាក់ បានចាប់ផ្តើមចូលលុកលុយអ៊ីរ៉ាក់ដើម្បីផ្តួលរំលំរបបដឹកនាំសាដាំ ហូសេន ដោយមានការគាំទ្រពីកងទ័ពអង់គ្លេស និងកងទ័ពសម្ព័ន្ធមិត្តមួយចំនួនទៀតរបស់ខ្លួន។ មុនការវាយលុកលើអ៊ីរ៉ាក់ អតីតប្រធានាធិបតី អាម៉េរិក លោក George W. Bush បានទុកពេលឱ្យលោក សាដាំ ហូសេន ៤៨ម៉ោងដើម្បីចុះចេញពីអំណាច ប៉ុន្តែមេដឹកនាំរូបនេះបានបដិសេធ ទើបលោក Bush ចេញបញ្ជាឱ្យយោធាអាម៉េរិក បាញ់មីស៊ីល Tomahawk ចូលក្នុងទីក្រុងបាកដាដ ហើយនៅដើមខែមេសា ឆ្នាំដដែល ទីក្រុងបាកដាដ ទាំងស្រុងបានធ្លាក់ចូលក្រោមដៃអាម៉េរិក រីឯរូបសំណាក សាដាំ ហូសេន ក៏ត្រូវបានគេបំផ្លាញចោលផងដែរ។ ប្រទេសនីមួយៗមានទំនាក់ទំនងក៏ព្រោះតែផលប្រយោជន៍របស់ខ្លួន ដូច្នេះយើងក៏មិនគួរបោះបង់ឱកាសនៃការទទួលផលចំណេញពីចិននោះទេ។ ជាពិសេសនោះ អាម៉េរិកមានទំនាក់ទំនងល្អជាមួយជាកុម្មុនីស្តវៀតណាម និងផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចឱ្យវៀតណាមច្រើន ចំណែកកម្ពុជាសេរីពហុបក្សអាម៉េរិកលូកដៃកិច្ចការផ្ទៃក្នុងរបស់កម្ពុជា។ អាម៉េរិកអាចមានទំនាក់ទំនងល្អជាមួយកម្ពុជាដរាបណាអាម៉េរិកយកវិនិយោគមកដាក់កម្ពុជា បើអាម៉េរិកចង់ទប់ឥទ្ធិពលចិនដរាបណាអាម៉េរិកយកវិនិយោគមកដាក់កម្ពុជា។

[10] ក្នុងពិធីបើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង និងប្រកាសសម្ពោធដាក់ឱ្យដំណើរការផ្លូវការរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំការមន កាលពីព្រឹកថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១។

## ២.៥.ទំនាក់ទំនងចិន-កម្ពុជាក្នុងបរិបទអាស៊ាន

អាស៊ីអាគ្នេយ៍គឺជាតំបន់ជិតខាងដ៏ធំមួយសម្រាប់ប្រទេសចិនដែលវាត្រូវបានតភ្ជាប់ដោយដីគោកនិងសមុទ្រចិនខាងត្បូង។ អាស៊ានបានក្លាយជាសហគមន៍មួយដែលមានទំនាក់ទំនងជាមួយចិនដោយទំនាក់ទំនងនេះមានមូលដ្ឋានពីរគឺ**ទី១**.ទំនាក់ទំនងទ្វេភាគីប្រទេសមួយដោយឡែកៗ **ទី២**.ទំនាក់ទំនងសមូហភាពជាមួយអាស៊ានទាំងមូល។ ទំនាក់ទំនងទ្វេភាគីមានភាពស្មុគស្មាញជាមួយប្រទេសនីមួយៗ តែប្រទេសចិនបានផ្តល់អាទិភាពក្នុងការអភិវឌ្ឍទំនាក់ទំនងជាមួយអាស៊ាន។ ប្រសិនបើមានការកើនឡើងជម្លោះនៅសមុទ្រចិនខាងត្បូង ប្រាកដណាស់ច្បាស់ថាទំនាក់ទំនងចិនជាមួយអាស៊ានត្រូវបានជះឥទ្ធិពលអវិជ្ជមានអាក្រក់ចំពោះចិន។

នៅចន្លោះទសវត្សរ៍ទី៦០និងទសវត្សរ៍ទី៧០ បណ្តាប្រទេសអាស៊ីអាគ្នេយ៍តែងតែចាត់ទុកចិនថាជាគ្រោះថ្នាក់មួយធំ។ កាលជំនាន់នោះចិន ជាគ្រោះថ្នាក់កុម្មុយនិស្តសម្រាប់ឥណ្ឌូណេស៊ី ថៃ ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន ឬភូមា។ ប្រទេសទាំងនេះខ្លាចចិនខ្លាំង និងព្រួយបារម្ភខ្លាំងជាពិសេសនៅក្នុងឆ្នាំ១៩៧៥ នាពេលដែលឥណ្ឌូចិនទាំងមូលក្លាយជាកុម្មុយនិស្ត។ ក្រោយមកទៀត នៅឆ្នាំ១៩៧៩ បណ្តាប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើននាំគ្នាចាត់ទុកចិនថា ជាគ្រោះថ្នាក់យោធា ពីព្រោះកាលនោះ កងទ័ពចិនបានវាយប្រហារទៅលើប្រទេសវៀតណាមដែលហ៊ានវាយរំលំរបបខ្មែរក្រហម និងហ៊ានចូលកាន់កាប់ប្រទេសកម្ពុជា។ [11] ហើយក៏ជាការប្រឈមមុខដាក់គ្នារវាងចិននិងសហរដ្ឋអាម៉េរិកដែលគេតែងនិយាយខ្លីថាជាសង្គ្រាមត្រជាក់ ប៉ុន្តែបច្ចុប្បន្នអាស៊ានគាំទ្រគោលការណ៍ប្រទេសចិនតែមួយទោះជាយ៉ាងណាចំពោះទិន្នភាពជាក់ស្តែងអាស៊ានសម្លឹងចិនផង អាស៊ានសម្លឹងសហរដ្ឋអាម៉េរិកផង។

ចំពោះទំនាក់ទំនងចិន-កម្ពុជានៅក្នុងបរិបទអាស៊ាន នៅឆ្នាំ២០១៨ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់នូវស្ពានអាកាសមិត្តភាពកម្ពុជា-ចិន សែនសុខ ប្រវែង ៩៤២ម៉ែត្ររដ្ឋាភិបាលកម្ពុជាបានលើកឡើង៥ចំណុចៈ[12]

### ១.កម្ពុជា ក៏ដូចអាស៊ានទាំង ១០ ទទួលផលប្រយោជន៍ធំពីចិន

មិនមែនគ្រាន់តែកម្ពុជាខ្លួនឯងទេ អាស៊ាន ១០ ទទួលផលប្រយោជន៍ធំណាស់។ ទំនាក់ទំនងតំបន់ពាណិជ្ជកម្មសេរី រវាងអាស៊ាន-ចិន នាំមកនូវប្រយោជន៍ពិតប្រាកដ។ អាស៊ាន មានទំនិញនាំចេញទៅកាន់ប្រទេសចិន។ បើប្រៀបធៀប ការនាំចេញពីប្រទេសចិន មកប្រទេសអាស៊ានមានចំនួនតិចជាង ពីប្រទេសអាស៊ានទៅកាន់ប្រទេសចិន។ ទេសចរពីប្រទេសអាស៊ាន ទៅកាន់ប្រទេសចិនមានចំនួនតិចជាង បើប្រៀបធៀបទេសចរប្រទេសចិន មកកាន់ប្រទេសអាស៊ាន។

### ២.តើយើងត្រូវទទួលទេសចរចិន ឬត្រូវទទួលអ្នកភៀសខ្លួនចិន ?

នៅឆ្នាំ ២០០១ នៅពេលដែលចិនមិនទាន់ចូលអង្គការពាណិជ្ជកម្មពិភពលោក ពេលនោះមានអ្នកសារព័ត៌មាន នៅទីក្រុងតូក្យូ នៅក្នុងសន្និសីទអន្តរជាតិមួយ ដែលរៀបចំដោយអង្គការសិទ្ធិមនុស្សរាប់ពាន់នាក់ ចូលរួមនៅទីនោះ។ រដ្ឋាភិបាលកម្ពុជាបានក្លាយទៅជា អ្នកធ្វើសុន្ទរកថាគន្លឹះ រួចហើយទុកពេលវេលា ដើម្បីឲ្យមានការឆ្លើយតបនូវសំណួរ។ មានសំណួរមួយចោទសួរ មកលើរដ្ឋាភិបាលថា តើមានការព្រួយបារម្ភអំពីឥទ្ធិពលរបស់ចិនឬទេ នៅ

---

[11] តាន់ ហ្សង់-ហ្វ្រង់ស័រៈ ចុះផ្សាយថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ៖ "អាស៊ាន និងចិន ៖ទំនាក់ទំនងបង្កប់ទៅដោយការមិនទុកចិត្ត" វិទ្យុបារាំង https://www.rfi.fr/km/china-asean ( accessed January 21, 2021 at 2:02pm )។

[12] សេចក្តីដកស្រង់ប្រសាសន៍ សម្តេចស្ពានអាកាសមិត្តភាព កម្ពុជា-ចិន សែនសុខ ដែលមានប្រវែង៩៤២ម៉ែត្រថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ នៅក្នុងរាជធានីភ្នំពេញ

ពេលដែលចិនចូលអង្គការពាណិជ្ជកម្មពិភពលោក? រដ្ឋាភិបាលកម្ពុជាបានឆ្លើយតបច្រើន ក៏ប៉ុន្តែន័យដែលធំជាងគេ គឺថា តើយើងត្រូវទទួលទេសចរចិន ឬត្រូវទទួលអ្នកភៀសខ្លួនចិន? នេះគឺជាចំណុចដែលធំជាងគេ នៅក្នុងចំណោមចម្លើយ ... ចិនមិនដែលនាំកងទ័ពចេញក្រៅព្រំដែនរបស់ចិនទេ។ ចិនក៏មិនអាចមាននរណាមួយ រារាំងមិនឲ្យរីកចម្រើនបានដែរ។ ប៉ុន្តែចម្លើយដែលធំជាងគេ ចោទចេញជាសំណួរថា តើត្រូវទទួលទេសចរចិន ឬត្រូវទទួលអ្នកភៀសខ្លួនចិន? នៅក្នុងសម័យអតីតកាល ចិនត្រូវទទួលគ្រោះទុរភិក្ស ការបែកបាក់ និងការឈ្លានពានពីបរទេស មានជនជាតិចិនជាច្រើនបានរត់មកកាន់អាស៊ីអាគ្នេយ៍ ក្នុងនោះក៏បានរត់មកកម្ពុជាសព្វថ្ងៃនេះ។ សូម្បីទៅសួរមើល អ្នកនៅផ្សារអូរឡាំពិក ផ្សារអូរឬស្សីអីហ្នឹងមួយចំនួន អ្នកនៅតាមដងទន្លេមេគង្គអីមួយចំនួនហ្នឹង គឺអ្នកដែលរត់មកពីស្រុកចិន។

**៣.ចំនួនអ្នកចូលឆ្នាំចិនពីសម័យដើមប្រហែលជា ២០% ឥឡូវឡើងទៅដល់ ៦០% ឬ ៧០%**

១០០ ឆ្នាំមុន ក៏មាន ហើយនៅក្នុងសម័យក្រោយ ១០០ ឆ្នាំ ប្រហែលជា ៨០ ឆ្នាំមុនក៏មានអ្នករត់ពីប្រទេសចិន ... បានជាចូលឆ្នាំចិនម្តងៗ សុទ្ធតែបិទក្រដាស មិនដឹងជាចិនស្អីនឹងគេដែរទេ អត់ចេះចិនអីមួយម៉ាត់ ហើយនាំគ្នាថាចូលឆ្នាំចិន។ កាលពីដើមចូលឆ្នាំចិនប្រហែលជា ២០% ឥឡូវអ្នកចូលឆ្នាំចិននឹងឡើងទៅដល់ ៦០% ឬ ៧០% ព្រោះកាលណាតែយកគ្នា(ជាប្តីប្រពន្ធ) នឹងជាប់ខ្សែ។ ចេះតែទៅហើយ។ មិនដឹងជាចិនមកពីកន្លែងណាទេ។ សម័យនោះគឺវាយ៉ាងដូច្នេះ។ រត់ពីប្រទេសចិន មកកាន់ប្រទេសថៃ ទៅកាន់ឥណ្ឌូនេស៊ី ទៅកាន់ម៉ាឡេស៊ី ទៅកាន់ប្រទេសនានា។ ទៅឆ្ងាយជាងហ្នឹងទៀត។ មកកាន់កម្ពុជា មកកាន់វៀតណាម ... បើសិនប្រទេសចិនបច្ចុប្បន្ន ដែលមានប្រជាជន ១៣៥០ លាននាក់ជាង ជិត ១៤០០ លាននាក់ ហើយស្រាប់តែមានកលិយុគ រត់ចេញត្រឹមតែ ៣០ លាននាក់ ... អាចថាមកឥណ្ឌូនេស៊ី ទៅម៉ាឡេស៊ី ទៅសាំងហ្គាពួរ ទៅថៃ ទៅវៀតណាម ទៅដទៃទៀត ឯកម្ពុជាត្រឹមតែកន្លះលាននាក់ហ្នឹង លៀនអណ្តាតបាត់ទៅហើយ ... ឥឡូវនេះយើងមិនទទួលនូវជនភៀសខ្លួនចិនទេ យើងទទួលនូវទេសចរចិន។

**៤.បើចិនមិនមកវិនិយោគទេ យើងបានអគ្គិសនីពីណាមកប្រើសម្រាប់បច្ចុប្បន្ន**

យើងពិនិត្យមើល បើយើងអង្គុយរង់ចាំ ដោយគ្មានអ្នកវិនិយោគដទៃមកទេនោះ សួរថាអគ្គិសនីបច្ចុប្បន្នបានអគ្គិសនីណាយកមកប្រើប្រាស់។ ដាក់ជាសំណួរអញ្ចេះ។ អ្នកខ្លះ ប្រទេសខ្លះ ប្រណែនចំពោះប្រទេសចិន ហើយមកធ្វើការវាយប្រហារចំពោះកម្ពុជា។ ប៉ុន្តែសួរថា វារីអគ្គិសនីទាំងអស់ផ្គត់ផ្គង់រាប់ពាន់មេហ្គាវ៉ាត់ សម្រាប់ការប្រើប្រាស់បច្ចុប្បន្ននេះ តើមានប្រទេសណាមួយមកសុំដាក់ទុន ឬសុំដេញថ្លៃយកគំរោងនោះ? វាអត់មាន។ បានត្រឹមតែថា។ ដល់ពេលគេមកធ្វើ បានត្រឹមប្រណែន។

**៥.គេរកស៊ីជាមួយចិនបាន ហេតុអីក៏កម្ពុជាមិនអាច?**

ពេលវិបត្តិសេដ្ឋកិច្ច ប្រទេសនានាទប់ខ្លួនឯងឲ្យមាំ តាមរយៈការកាត់បន្ថយទុនចេញទៅក្រៅប្រទេស ក៏ប៉ុន្តែចិនអត់បានកាត់បន្ថយការបញ្ជូនទុន(ចេញក្រៅប្រទេស)ទេ។ មកវិនិយោគគម្រោងនានានៅក្នុងប្រទេសរបស់យើង មិនត្រឹមតែមិនកាត់បន្ថយ ថែមទាំងធ្វើលឿនមុនការកំណត់ទៀតផង។ ប្រទេសនានារកស៊ីជាមួយចិនយ៉ាងច្រើន ម៉េចបានជាមកហាមឃាត់កម្ពុជាមិនអោយរកស៊ីជាមួយចិន? ។ បើប្រទេសនៅអឺរ៉ុប សុទ្ធតែជិះយន្តហោះមកចរចាជាមួយចិននៅប៉េកាំង ដើម្បីបង្កើតការនាំទំនិញ ការវិនិយោគ។

នៅពេលកិច្ចប្រជុំកំពូលអាស៊ាន-ចិនលើកទី២១ ឆ្នាំ២០១៨បានប្រព្រឹត្តិទៅក្រោមប្រធានបទ «ការពិនិត្យឡើងវិញនូវកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន និងទិសដៅអនាគត»។ កម្ពុជាមានជំនឿយ៉ាងមុតមាំថា ចិនគឺជាដៃគូយុទ្ធសាស្ត្រមួយមិនអាចខ្វះបានរបស់អាស៊ាន ទោះស្ថិតនៅក្នុងកាលៈទេសៈ និងបរិការណ៍ណាក៏ដោយ ហើយសង្ឃឹមថា ទំនាក់ទំនងនេះនឹងកាន់តែស្ថិតស្ថេរជ្រាលជ្រៅក្នុងស្មារតីតម្កល់ផលប្រយោជន៍រួម និងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្នជូនប្រជាជាតិទាំងអស់។ ទន្ទឹមនឹងនោះដែរ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងនូវចំណុចគន្លឹះសំខាន់ៗចំនួន ៤ ក្នុងក្របខណ្ឌនៃការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងអាស៊ាន-ចិន ដែលក្នុងនោះរួមមានៈ[13]

១) កម្ពុជាគាំទ្រសេចក្តីថ្លែងការណ៍ ស្តីពីចក្ខុវិស័យភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន ឆ្នាំ ២០៣០ និងសេចក្តីប្រកាសរួមស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលនឹងជួយលើកកម្ពស់កិច្ចសហប្រតិបត្តិការបន្ថែមទៀត។ កម្ពុជានឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រទេសសមាជិកអាស៊ាន និងចិនដើម្បីអនុវត្តឲ្យបានពេញលេញ និងមានប្រសិទ្ធភាពនូវចក្ខុវិស័យយន្តការ និងទិសដៅខាងលើ សំដៅរួមចំណែកជំរុញកិច្ចសហប្រតិបត្តិការឱ្យកាន់តែរីកចម្រើន។

២) កម្ពុជាស្វាគមន៍ការកំណត់យកឆ្នាំ ២០១៩ ជាឆ្នាំផ្លាស់ប្តូរសារព័ត៌មានអាស៊ាន-ចិន ដោយសង្ឃឹមថា សមាជិកអាស៊ាន និងចិន នឹងផ្តល់អាទិភាពខ្ពស់ក្នុងការអនុវត្តនូវសកម្មភាព និងគម្រោងនានាពាក់ព័ន្ធនឹងវិស័យព័ត៌មាន សំដៅជំរុញការយល់ដឹងអំពីទំនាក់ទំនងអាស៊ាន-ចិន លើគ្រប់វិស័យ ជាពិសេសរួមចំណែកដល់ការកសាងជំនឿ និងទំនុកចិត្តដើម្បីជាស្ពានមិត្តភាពរវាងប្រជាជន និងប្រជាជន។

៣) កម្ពុជាវាយតម្លៃខ្ពស់ចំពោះការពង្រឹងកិច្ចសហប្រតិបត្តិការរបស់ចិន ពាក់ព័ន្ធនឹងវិស័យតភ្ជាប់ និងការបន្តការគាំទ្ររបស់ចិនក្នុងការអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ ២០២៥ ជាពិសេសកិច្ចខិតខំប្រឹងប្រែងរិះរកភាពរួមបញ្ចូលគ្នា និងការបំពេញឲ្យគ្នាទៅវិញទៅមករវាងគំនិតផ្តួចផ្តើម នៃផែនការមេ ស្តីពីការតភ្ជាប់អាស៊ាន និងគំនិតផ្តួចផ្តើម ខ្សែក្រវាត់មួយ ផ្លូវមួយ របស់ចិន និង

៤) កម្ពុជា គាំទ្រការបន្តពង្រឹង និងពង្រីកវិសាលភាព កិច្ចសហប្រតិបត្តិការ ក្នុងវិស័យពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍ រវាងអាស៊ាន និងចិន ឲ្យកាន់តែខ្លាំងឡើងមួយកម្រិតទៀត ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់យើងប្រកបដោយចីរភាព និងបរិយាប័ន្ន។

[13] http://km.cnv.org.kh/៖ ចុះផ្សាយថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ៖ "សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូល អាស៊ាន-ចិន លើកទី ២១", km.cnv.org.kh/2018/ប្រជុំអាស៊ាន-ចិន-លើកទី-២/ (accessed January 12, 2021 at 9:29pm).

## ២.៦.កិច្ចសហប្រតិបត្តិការមេគង្គ

ទាក់ទងទៅនឹងតំបន់មេគង្គសម្តេចតេជោ ហ៊ុន សែន បានចែករំលែកទស្សនៈមួយចំនួន ពាក់ព័ន្ធនិងចក្ខុវិស័យរួម និង ទិសដៅអភិវឌ្ឍន៍សម្រាប់តំបន់មេគង្គ៣ចំណុចៈ[14]

**ទី១**-«**សក្តានុពលនៃតំបន់មេគង្គ ក្នុងការប្រែក្លាយជាមជ្ឈមណ្ឌលផលិតកម្មធំមួយក្នុង តំបន់ និងពិភពលោក**» ក្នុងរយៈពេលមួយទៅពីរទសវត្សរ៍ខាងមុខ។ តំបន់មេគង្គ ស្ថិតក្នុងភូមិសាស្រ្តសេដ្ឋ-កិច្ច និងនយោបាយមួយអំណោយផលនៅចំកណ្តាលបេះដូងនៃអាស៊ាន ស្ថិតក្នុងតំបន់អាស៊ី ដែលមាន កំណើនខ្ពស់ នៅចន្លោះមហាអំណាចសេដ្ឋកិច្ចធំពីរ គឺ **ចិន** និង **ឥណ្ឌា** និងមានច្រកចេញទៅសមុទ្រ សម្រាប់ផ្សារភ្ជាប់ទៅនឹងសេដ្ឋកិច្ច និងពាណិជ្ជកម្មពិភពលោក។ គិតត្រឹមឆ្នាំ ២០៣០ ប្រទេសទាំងប្រាំ នឹង មានប្រជាជនប្រមាណ ២៦០ លាននាក់ ក្នុងចន្លោះ ៦៥% ជាកម្លាំងពលកម្មសកម្ម ដែលមានសារៈ សំខាន់សម្រាប់ការអភិវឌ្ឍឧស្សាហកម្មតំបន់។

ដូច្នេះយើងមានសក្តានុពលសម្រាប់បង្កើតបណ្តាញផលិតកម្មតំបន់មួយ ប្រកបដោយភាពប្រកួតប្រជែង និងប្រសិទ្ធិភាពខ្ពស់ ដែលនឹងអាចបែងចែកប្រយោជន៍សមស្របដល់ប្រទេសចូលរួមនីមួយៗ នៅក្នុងខ្សែ ចង្វាក់តម្លៃ និងការផ្គត់ផ្គង់។ ការតភ្ជាប់ភ្ជាប់បណ្តាញផលិតកម្មបែបនេះ នឹងជួយពន្លឿនការអភិវឌ្ឍបច្ចេក- វិទ្យា តាមរយៈការបំពេញឲ្យគ្នាទៅវិញទៅមក រវាងប្រទេសដែលមានឧស្សាហកម្មឈានមុខ គឺ **ថៃ** និង **វៀតណាម** និងប្រទេសជួរក្រោយ គឺ **កម្ពុជា ឡាវ** និង **មីយ៉ាន់មា** ដែលនឹងផ្គុំជាខ្សែចង្វាក់ផលិតកម្មតំបន់ មួយប្រកបដោយជវភាព។

**ទី២**-ដើម្បីសម្រេចចក្ខុវិស័យនេះ ប្រទេសទាំងប្រាំត្រូវផ្តោតលើការថែរក្សាសន្តិភាព និងស្ថិរភាពតំបន់ជាអាទិភាពចម្បងបំផុត និងត្រូវរួមគ្នាដោះស្រាយឧបសគ្គធំៗ ចំពោះភាពប្រកួតប្រជែងតំបន់ ដោយផ្តោតជា សំខាន់**លើការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ថាមពល និងឌីជីថល ការធានាចលនាដោយសេរី និងប្រកប ដោយប្រសិទ្ធិភាពនៃលំហូរពាណិជ្ជកម្ម និងការវិនិយោគ ព្រមទាំងការអភិវឌ្ឍមូលធនមនុស្ស។** កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងដែនក៏ដូចជាការអភិវឌ្ឍតំបន់ឧស្សហកម្មតាមច្រករបៀងតំបន់ និងតំបន់ សេដ្ឋកិច្ចពិសេសឆ្លងដែន គឺជាចំណុចចាប់ផ្តើមគន្លឹះ។ វិស័យឯកជនត្រូវដើរតួនាទីសកម្មនៅក្នុងការតភ្ជាប់ សេដ្ឋកិច្ចតំបន់ ពិសេសការចូលរួមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ តាមរយៈគម្រោងភាពជាដៃគូរដ្ឋ និងឯកជន ទន្ទឹមនេះ រដ្ឋត្រូវធានាបរិយាកាសអាជីវកម្មល្អប្រសើរ។ «**គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់មួយ-ផ្លូវមួយរបស់ចិន**» ព្រមទាំងយន្តការមូលនិធិផ្លូវសូត្រ ធនាគារ AIIB និង ADB នឹងដើរតួដ៏សំខាន់ក្នុងការផ្តល់ហិរញ្ញប្បទាន ដល់គម្រោងផ្លូវហាយវេ ផ្លូវរថភ្លើង កំពង់ផែ ផ្លូវអាកាស ក៏ដូចជាបណ្តាញថាមពល និងបណ្តាញទូរគមនា- គមន៍ រួមទាំងការសម្របសម្រួលខាងស្ថាប័ន និងនិយ័តកម្មផង ដើម្បីបម្រើឲ្យការតភ្ជាប់តំបន់នេះទាំងផ្នែក រឹង ទាំងផ្នែកទន់។

**ទី៣**-សម្រាប់កម្ពុជា យើងមានចំណុចពិសេសច្រើន ដែលសមស្របសម្រាប់អនុវត្តចក្ខុវិស័យនេះ រួមមានៈ (១)-ជាប្រទេសមានសក្តានុពលកំណើនខ្ពស់ ដែលគាំទ្រដោយផលលាភប្រជាសាស្រ្ត និងធនធានធម្មជាតិ សម្បូរបែប។ រាជរដ្ឋាភិបាលកម្ពុជាដាក់ជំនឿខ្ពស់លើសមាហរណកម្ម និងការតភ្ជាប់តំបន់ ដោយបានខិតខំ ប្រឹងប្រែងស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាច្រើនក្នុងរយៈពេលជាងពីរទសវត្សកន្លងមកនេះ ដើម្បីតភ្ជាប់ ជាមួយប្រទេសជិត

[14] http://km.cnv.org.kh/៖ ចុះផ្សាយថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ៖ "សុន្ទរកថាក្នុងវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីតំបន់មេគង្គ, ពិធីបើកកិច្ចប្រជុំពេញអង្គ «ការស្វែងរកថាមភាពសំយោគៈ ថ្នាក់ដឹកនាំតំបន់ចែករំលែកនូវចក្ខុវិស័យសម្រាប់តំបន់មេគង្គ»"km.cnv.org.kh/2016/វេទិកាសេដ្ឋកិច្ចពិភពលោ/ (accessed February 3, 2021 at 3:02pm)។

ខាង។ ក្នុងន័យនេះ កម្ពុជាបានត្រៀមរួចជាស្រេច ដើម្បីសហការជាមួយប្រទេសមេគង្គ ក្នុងការឈានទៅសម្រេចនូវចក្ខុវិស័យដូចលើកឡើងខាងលើ ពិសេសក្នុងបរិការណ៍នៃបដិវត្តន៍ឧស្សហកម្ម ទី ៤ នាសតវត្សថ្មីនេះ។ ដោយយល់ឃើញថា ខ្សែចង្វាក់ផ្គត់ផ្គង់តំបន់ ដើរតួនាទីជាក្បាលម៉ាស៊ីនថ្មីសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច កម្ពុជាបានអនុម័តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥ កាលពីឆ្នាំទៅ ហើយត្រៀមលក្ខណៈស្វាគមន៍វិនិយោគិនទាំងអស់ ដើម្បីចូលរួមចំណែកអភិវឌ្ឍកម្ពុជា និងទទួលចែករំលែកផលផ្លែផ្កាពីកិច្ចប្រឹងប្រែងនេះ។

## ៣.ជំនួយចិនមកកម្ពុជា

### ៣.១.ចិន ផ្តល់ជំនួយឥតសំណងជាង ១៧៤លានដុល្លារ សម្រាប់ការអភិវឌ្ឍនៅកម្ពុជា

នៅឆ្នាំ២០១៧ កម្ពុជានិងចិនបានចុះហត្ថលេខា ស្តីពីការផ្តល់ ជំនួយឥតសំណងជាង ១៧៤លានដុល្លារស្តីពីការផ្តល់ ជំនួយឥតសំណងជាង ១៧៤លានដុល្លារ និងបានចុះកិច្ចព្រមព្រៀងសំខាន់ៗទាំង៦៖[15]

ទី១៖ពិធីសារស្តីពី បង្កើតស្ថានីយ៍ សង្កេតកិច្ចការបរិស្ថានសមុទ្ររួម។

ទី២៖ កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស លើការផ្តល់ហិរញ្ញប្បទាន ឥតសំណងចំនួន ១២០០លានយ័នស្មើជាង ១៧៤លានដុល្លារសម្រាប់ឆ្នាំ២០១៧។

ទី៣៖ កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់ដុល្លារ សម្រាប់គម្រោងសាងសង់ខ្សែ បញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុល ជំហានទី២ នៅភាគខាងកើតប្រទេសកម្ពុជា។

ទី៤៖ អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើការកសាងសមត្ថភាព ពាក់ព័ន្ធវិស័យដឹកជញ្ជូន។

ទី៥៖ អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងផែនការ សកម្មភាព ដើម្បីអនុវត្តអនុស្សារណៈ នៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍។

ទី៦៖ ឯកសារស្តីពីចំណុចគោលនៃផែនការកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីរួមគ្នាបង្កើតកិច្ចសហប្រតិបត្តិការ ខ្សែក្រវ៉ាត់ សេដ្ឋកិច្ចផ្លូវសូត្រ និងកិច្ចសហប្រតិបត្តិការផ្លូវសូត្រសមុទ្រសតវត្សរ៍ទី២១ រវាងកម្ពុជា និងចិន។

### ៣.២.ជំនួយយោធា

គិតត្រឹមថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៩ រដ្ឋាភិបាលចិន បន្តផ្តល់ជំនួយឥតសំណង រហូតដល់ ៦០០លានយ័ន ស្មើនឹងប្រមាណ ៨៤លានដុល្លារអាម៉េរិក ដល់ប្រទេសកម្ពុជា សម្រាប់ពង្រឹងវិស័យការពារជាតិ បន្ថែមពីលើអ្វីដែលធ្លាប់ចុះកិច្ចព្រមព្រៀងកន្លងមក។ ទំហំទឹកប្រាក់ដែលមហាមិត្តចិនបង្កើននេះ គឺជាការបញ្ជាក់អំពីការពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកម្ពុជា-ចិន។[16]

---

[15] កម្ពុជាទស្សនៈថ្មី៖ ចុះផ្សាយថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ៖ "ចិន ផ្តល់ជំនួយឥតសំណងជាង ១៧៤លានដុល្លារ សម្រាប់ការអភិវឌ្ឍនៅកម្ពុជាក្នុងឆ្នាំ២០១៧", km.cnv.org.kh/2017/ចិន-ផ្តល់ជំនួយឥតសំណងជាង/ (accessed March 22, 2018, at 10:56am)។

[16] គណបក្សប្រជាជនកម្ពុជា៖ ចុះផ្សាយថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ៖ "ចិនបន្តផ្តល់ជំនួយឥតសំណងប្រមាណ ៨៤លានដុល្លារ សម្រាប់ពង្រឹងវិស័យការពារជាតិកម្ពុជា" https://www.cpp.org.kh/details/161546 (December 4, 2019 at 1:01pm)។

ក.ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ រដ្ឋាភិបាលចិនបានបញ្ជូនក្រុមអ្នកជំនាញវេជ្ជសាស្ត្រ៧រូប រួមជាមួយឧបករណ៍ សម្ភារពេទ្យមួយចំនួន បានមកដល់ប្រទេសកម្ពុជា ដែលជាក្រុមអ្នកជំនាញប្រឆាំងជំងឺកូវីដ-១៩ ដំបូងដែលប្រទេសចិនបានបញ្ជូនចេញទៅបេសកកម្ម នៅតំបន់អាស៊ីអាគ្នេយ៍ «អាស៊ាន»។

ខ.នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ក្រុមអ្នកជំនាញវេជ្ជសាស្ត្រនៃកងទ័ពរំដោះប្រជាជនចិនចំនួន៤រូប ដឹកនាំដោយលោកវរសេនីយ៍ឯកពិសេស ជាង ជៃ ហ្វូ (Jiang Jia fu) ដែលជាក្រុមគ្រូពេទ្យកងទ័ពចិន មានសមត្ថភាពពោរពេញដោយបទពិសោធន៍ខ្ពស់ បានបំពេញបេសកកម្មទៅក្រៅប្រទេសជាច្រើនដង ដូចជា ចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ បានមកដល់ប្រទេសកម្ពុជា វិញ ដែរ។ ក្រុមនេះបានចូលរួមក្នុងការស្រាវជ្រាវនៅនឹងកន្លែងផ្ទាល់ ដែលមានការឆ្លងកាត់ ក្នុង ស្ថានភាពធ្ងន់ធ្ងរក្នុងប្រទេសចិនអស់ជាច្រើនលើកមកហើយ។[17]

គ.នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ កងទ័ពរំដោះប្រជាជនចិន ប្រគល់សម្ភារ បរិក្ខារពេទ្យប្រមាណជាង២តោន សម្រាប់បង្ការ ទប់ស្កាត់ជំងឺ COIVD-19 ជូនដល់ក្រសួងការពារជាតិកម្ពុជា។ ការផ្តល់ជំនួយសម្ភារ បរិក្ខារសុខាភិបាល ការបង្ហាត់បង្រៀន ការប្រើប្រាស់ ប្រព័ន្ធបច្ចេកទេសទំនើប និងវិទ្យាសាស្ត្រ ប្រកបដោយវិជ្ជាជីវៈរបស់ក្រុមគ្រូពេទ្យចិន ដែលមានបទពិសោធន៍ក្នុងការប្រយុទ្ធប្រឆាំងនឹងវីរុសកូវីដ-១៩នោះ នឹងជួយដល់ស្ថាប័នសុខាភិបាលក្នុងជួរកងយោធពលខេមរភូមិន្ទ ឱ្យកាន់តែមានសមត្ថភាព ដើម្បីបង្ការ ទប់ស្កាត់ និងការពារជំងឺឆ្លងនានា។[18]

## ៣.៣.ចិនបានផ្ដល់ជំនួយ១លានដុល្លារ ដល់វិស័យសកម្មភាពមីននៅកម្ពុជា

ជំនួយដ៏សប្បុរសរបស់មហាមិត្តចិន សម្រាប់ការងារបោសសម្អាតមីននៅកម្ពុជាកម្ពុជាបានបង្ហាញពីការទទួលបានជោគជ័យ ក្នុងការអនុវត្តនូវផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ គឺឆ្ពោះទៅរកកម្ពុជាមួយដែលគ្មានមីនឆ្នាំ២០២៥ ជាពិសេសចូលរួមដល់ការជួយសង្គ្រោះជីវិតមនុស្ស ការចូលរួមកាត់បន្ថយភាពក្រីក្រ និងការកសាងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង។ ជំនួយឥតសំណងនោះគិតជាប្រាក់ប្រមាណ១លានដុល្លារអាមេរិក រួមមានរថយន្ត Pick Up ចំនួន៨គ្រឿង, ឧបករណ៍រាវមីនចំនួន១៣០គ្រឿង, ប្រអប់សម្ភារៈចំនួន១០០ឈុត, ប្រអប់សម្ភារៈបំផ្ទុះគ្រាប់ (EOD) ចំនួន២០ឈុត, សម្លៀកបំពាក់ការពារចំនួន១០កំផ្លេ, មួកការពារចំនួន១០, ដ្រូន (UAV) ចំនួន៤គ្រឿង, ឯកសណ្ឋាន, ស្បែកជើង និងមួក ចំនួន ៥០០ កំផ្លេ និងតង់ចំនួន៥០០តង់។[19]

---

1717 ក្រសួងព័ត៌មានៈ ចុះផ្សាយថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ៖ "ឯកអគ្គរដ្ឋទូតចិនៈ រដ្ឋាភិបាល ប្រជាជន និងកងទ័ពចិន មិនអាចបំភ្លេចបានឡើយ នៅពេលដែលកម្ពុជាជួបការលំបាកនៃការរីករាលដាលជំងឺកូវីដ-១៩", https://www.information.gov.kh/articles/18326 (accessed April 02, 2020 at 9:29pm)។

18 ក្រសួងព័ត៌មានៈ ចុះផ្សាយថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ៖ "កងទ័ពរំដោះប្រជាជនចិន ប្រគល់សម្ភារ បរិក្ខារពេទ្យប្រមាណជាង២តោន សម្រាប់បង្ការ ទប់ស្កាត់ជំងឺ COIVD-19 ជូនដល់ក្រសួងការពារជាតិកម្ពុជា" https://www.information.gov.kh/articles/18244 (accessed January April 2, 2020 at 3:92pm)

19 អគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍អប្សរា ams ៖ ចុះផ្សាយថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ ៖ "ចិនផ្តល់ជំនួយ១លានដុល្លារ ដល់វិស័យសកម្មភាពមីននៅកម្ពុជា", https://ams.com.kh/central/detail/241075 (accessed January 29, 2021 at 11:08am)។

## ៣.៤.វិស័យធារាសាស្ត្រនៅកម្ពុជា

ដោយគិតពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៩ រដ្ឋាភិបាលចិនបានផ្តល់ឥទានការប្រាក់ទាប ក្នុងការកសាង ស្តារ ប្រឡាយមេធំ ប្រឡាយមេ ប្រឡាយរំដោះទឹកមេ ប្រឡាយរំដោះទឹករង ប្រឡាយនាំទឹក និងអាងស្តុកទឹកជាដើម ដែលគិតជាទឹកប្រាក់ប្រមាណ៩០០លានដុល្លារអាមេរិក។ ទឹកប្រាក់ជាង៩០០លានដុល្លារ ត្រូវបានក្រសួងធនធានទឹក និងឧតុនិយម យកមកប្រើប្រាស់លើគម្រោងចំនួន១៣ និងគម្រោងខ្លះធ្វើឡើងចំនួន២ជំហាន។ គម្រោងទាំង១៣រួមានៈ[20]

១.គម្រោងអភិវឌ្ឍន៍ស្រោចស្រពកង្ហតខេត្តបាត់ដំបង ដែលបានចាប់ផ្តើមនៅឆ្នាំ២០០៩ និងបញ្ចប់ទាំងស្រុងនៅឆ្នាំ២០១៥។

២.គម្រោងការពារទឹកជំនន់ទន្លេកំពង់ត្របែក នៅខេត្តព្រៃវែង ដែលបានចាប់ផ្តើមកសាងនៅឆ្នាំ២០០៩ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៥។

៣.គម្រោងអភិវឌ្ឍន៍ធនធានទឹកព្រែកស្ទឹងកែវ ខេត្តកំពត ដែលបានចាប់ផ្តើមកសាងនៅឆ្នាំ២០០៩ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៥។

៤.គម្រោងអភិវឌ្ឍន៍ស្ទឹងពោធិ៍សាត់ទំនប់លេខ៣ និងលេខ៥ ខេត្តពោធិ៍សាត់ ផ្តើមកសាងនៅឆ្នាំ២០១០ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៦។

៥.គម្រោងអភិវឌ្ឍន៍ស្រោចស្រពកង្ហតជំហាន២ នៅខេត្តបាត់ដំបង ផ្តើមកសាងនៅឆ្នាំ២០១១ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៦។

៦.គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រវ៉ៃកូជំហាន១ នៅខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង ផ្តើមកសាងនៅឆ្នាំ២០១១ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៧។

៧.គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងស្រែង ខេត្តសៀមរាប បន្ទាយមានជ័យ និងឧត្តរមានជ័យ ផ្តើមកសាងនៅឆ្នាំ២០១០ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៥។

៨.គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងស្ទោង ខេត្តកំពង់ធំ ផ្តើមកសាងនៅឆ្នាំ២០១២ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៨។

៩.គម្រោងអភិវឌ្ឍន៍ពហុបំណងបាត់ដំបង នៅខេត្តបាត់ដំបង ផ្តើមកសាងនៅឆ្នាំ២០១២ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៨។

១០.គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងជីក្រែង ជំហាន១ ខេត្តសៀមរាប ផ្តើមកសាងនៅឆ្នាំ២០១៣ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៨។

១១.គម្រោងអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពអាចាង ខេត្តកំពង់ឆ្នាំង ផ្តើមកសាងនៅឆ្នាំ២០១៣ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៨។

[20] គណបក្សប្រជាជនកម្ពុជា៖ ចុះផ្សាយថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០៖ "ទឹកប្រាក់ឥណទានប្រមាណ៩០០លានដុល្លារអាមេរិក ត្រូវបានចិនជួយលើវិស័យធារាសាស្ត្រនៅកម្ពុជា", https://www.cpp.org.kh/details/238326 (accessed February 1, 2021 at 7:29am)។

១២.គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងស្រែង ដំហាន២ ខេត្តឧត្តរមានជ័យ ផ្តើមកសាងនៅឆ្នាំ២០១៣ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៩។

១៣.គម្រោងអភិវឌ្ឍន៍ស្ទឹងពោធិ៍សាត់ទំនប់លេខ៣ និងលេខ៥ ដំហានទី២ ខេត្តពោធិ៍សាត់ ផ្តើមកសាងនៅឆ្នាំ២០១៦ និងបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៩។

## ៤.កម្ពុជា-ចិនគឺជាមិត្តដែកថែបនិងជាដៃគូសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ

### ៤.១.ផ្លូវមួយខ្សែក្រវ៉ាត់មួយ

"ផ្លូវមួយ ខ្សែក្រវ៉ាត់មួយ" របស់ចិន មានគំនិតផ្តួចផ្តើមចាប់តាំងពីឆ្នាំ២០១៣ របស់ប្រធានាធិបតីចិន ស៊ី ជីនពីង បានបង្កើតគម្រោងមហាសាល រួមមានការកសាង ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ខ្សែរថភ្លើង បំពង់បង្ហូរឧស្ម័ន និងកំពង់ផែជាច្រើនកន្លែង ដើម្បីផ្សារភ្ជាប់ចិនជាមួយនឹងទ្វីបអឺរ៉ុប អាស៊ី ដើមបូព៌ា និងអាហ្វ្រិក។ នៅឆ្នាំ២០១៨ ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា លោក ស្យុង បូ បានមានប្រសាសន៍ថា "ភាគីចិនមានបំណងជំរុញកិច្ចសហប្រតិបត្តិការជាក់ស្តែង និងគ្រប់វិស័យ ដូចជាការកសាង ខ្សែក្រវ៉ាត់ និងផ្លូវ ដើម្បីតម្រូវការជាក់ស្តែងរបស់កម្ពុជា សូមគាំទ្រក្នុងឲ្យលឿនកិច្ចសហប្រតិបត្តិការ ក្នុងការអភិវឌ្ឍ និងនាំមកនៅសុកមង្គល ជូនប្រជាជន ហើយរួមគ្នាជំរុញទំនាក់ទំនងមិត្តភាព ចិន-កម្ពុជាឲ្យវិវត្តន៍ទៅមុខទៀត"។[21] មុនការដាក់ចេញគម្រោងអនុវត្ត BRI កាលពីឆ្នាំ២០១៣ ការវិនិយោគរបស់ចិននៅកម្ពុជានាពេលនោះគឺផ្តោតសំខាន់តែលើគម្រោងថាមពលអគ្គិសនីដូចជាទំនប់វារីអគ្គិសនី ក៏ប៉ុន្តែបន្ទាប់ពីគម្រោង BRI ចាប់ផ្តើមអនុវត្តទុនវិនិយោគចិនបានបង្វែរមកវិស័យផ្សេងវិញជាពិសេសវិស័យអចលនទ្រព្យ និងវិស័យដឹកជញ្ជូន។ វិស័យទាំងនេះបូកបញ្ចូលគ្នាមានចំណែកទុនវិនិយោគដល់ទៅ ៧៣ ភាគរយនៃការវិនិយោគចិនសរុបនៅកម្ពុជា។ ក្នុងឆ្នាំ២០១៩ លំហូរវិនិយោគផ្ទាល់បរទេសនៅកម្ពុជាមានចំនួន ៣.៧ពាន់លានដុល្លារអាម៉េរិក កើនឡើង ១៥,២% ពីឆ្នាំ ២០១៨។ គិតត្រឹមខែតុលា ឆ្នាំ២០២០ មាន១៣៨ ប្រទេសនៅក្នុងបណ្តាទ្វីបទាំងបីនេះបានចុះកិច្ចព្រមព្រៀងចូលរួមអនុវត្ត BRIនេះ។ នៅ២០១៩ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា «ភាពជោគជ័យនៃការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ ដែលជាគម្រោងវិនិយោគដ៏ធំរបស់ចិន និងជាសក្ខីភាពមួយយ៉ាងច្បាស់នៃការកសាងគម្រោងផែនការសហប្រតិបត្តិការ «ខ្សែក្រវ៉ាត់ និងផ្លូវ» រវាងប្រទេសទាំងពីរ។ គម្រោងទាំងនេះទទួលបានជោគជ័យល្អប្រសើរ ហើយបច្ចុប្បន្នមានក្រុមហ៊ុនចំនួន១៦១ កំពុងធ្វើសហប្រតិបត្តិការ។ ក្នុងនោះមានក្រុមហ៊ុនចិនចំនួន១៤៨ និងបង្កើតការងារជូនប្រជាជនកម្ពុជាជាង ២ម៉ឺននាក់។»[22]

---

[21] ក្រសួងសាធារណការ និងដឹកជញ្ជូន៖ ចុះផ្សាយថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨៖ "[DAP] - ទូតចិន ៖ ផ្លូវមួយខ្សែក្រវ៉ាត់មួយ ដើម្បីបំពេញតម្រូវការ ជាក់ស្តែង នៅកម្ពុជា" https://www.mpwt.gov.kh/kh/press/2909 ( accessed April 3, 2019 at 9:29pm )

[22] bunthoeun chhut ៖ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២០៖ "ចិនផ្តោតខ្លាំងលើវិស័យអចលនទ្រព្យកម្ពុជា បន្ទាប់ពីមានគម្រោង «ផ្លូវមួយខ្សែក្រវ៉ាត់មួយ»" z1news, https://z1news.net/china-investment-shifted-to-towards-real-estate-after-bri-in-place/ ( accessed December 5, 2020 at 4:14pm )

គំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវ៉ាត់មួយកំណត់អាទិភាពចម្បងចំនួនប្រាំ៖[23]

(1) ការសម្របសម្រួលគោលនយោបាយ

(2) ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ

(3) ពាណិជ្ជកម្មគ្មានដែនកំណត់

(4) សមាហរណកម្មហិរញ្ញវត្ថុ

(5) និងការតភ្ជាប់មនុស្ស។

### ៤.២- ការគាំទ្ររបស់ចិនដល់កម្ពុជាក្នុងនីតិកាលទី៥ និងនីតិកាលទី៦នៃរដ្ឋសភា

ប្រធានាធិបតីចិន ស៊ី ជិនពីង បានគូសបញ្ជាក់ថា «ប្រទេសចិនជ្រោមជ្រែងប្រជាជនកម្ពុជាឱ្យបន្តដើរតាមវិថីនៃការអភិវឌ្ឍដែលសមស្របទៅនឹងលក្ខខណ្ឌនៃប្រទេសរបស់ខ្លួន»។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងថា «រដ្ឋាភិបាលនិងប្រជាជនកម្ពុជា វាយតម្លៃខ្ពស់ចំពោះជំនួយរយៈពេលវែងរបស់ចិន ព្រមទាំងពេញចិត្តនឹងចំណងមិត្តភាពរវាងចិននិងកម្ពុជាយ៉ាងខ្លាំង»។ ហើយសម្តេចក៏បានគូសបញ្ជាក់សារជាថ្មីថា «កម្ពុជានឹងបន្តដើរតួក្នុងន័យស្ថាបនា ដើម្បីបង្កើនចំណងមេត្រីភាពរវាងប្រទេសចិន និងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍»។[24]

### ៤.៣- ទំនាក់ទំនងភាពជាដៃគូចាក់ទឹកមិនលិច

ចាប់តាំងពីឆ្នាំ២០១០មក ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ចិន ត្រូវបានលើកកម្ពស់មួយកម្រិតទៅជាទំនាក់ទំនង «ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ» ដោយកម្ពុជាតែងតែគាំទ្រនយោបាយការបរទេសចិន ជាពិសេសគោលនយោបាយចិនតែមួយ និងគំនិតផ្តួចផ្តើមស្តីពី «ការផ្តួចផ្តើមគំនិងខ្សែក្រវាត់ និងផ្លូវ»។ កិច្ចសហប្រតិបត្តិការភាពដៃគូយុទ្ធសាស្ត្រ គ្រប់ជ្រុងជ្រោយកម្ពុជា-ចិន ត្រូវបានបន្តពង្រឹង តាមរយៈយន្តការគណៈកម្មាធិការសម្របសម្រួល អន្តររដ្ឋាភិបាលកម្ពុជា-ចិន ដែលត្រូវបានបង្កើត ឡើងនៅឆ្នាំ២០១៤ ហើយត្រូវបានរៀបចំប្រជុំ ជារៀងរាល់ឆ្នាំ។[25]

### ៤.៤. កំណើននិងឥទ្ធិពលនៃការវិនិយោគ ពាណិជ្ជកម្ម ចិនចំពោះកម្ពុជា

ក្នុងក្របខណ្ឌតំបន់ ប្រទេសចិនបានដាក់ចេញនូវគំនិតផ្តួចផ្តើម «ខ្សែក្រវ៉ាត់មួយ និងផ្លូវមួយ» បង្កើត «មូលនិធិផ្លូវសូត្រ» និង «ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី» ដើម្បីពង្រឹងភាពជាដៃគូ និងជំរុញការអភិវឌ្ឍបែប «ឈ្នះ-ឈ្នះ» រវាងប្រទេសក្នុងរង្វង់តំបន់ខ្សែក្រវាត់ និងផ្លូវសូត្រ តាមរយៈកិច្ចសហប្រតិបត្តិការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ស្ថាប័ន និងប្រជាជន វិស័យធុរកិច្ច ហិរញ្ញវត្ថុ វប្បធម៌ និងវិស័យគន្លឹះផ្សេងៗទៀត។ ប្រទេសទាំងពីរក៏បានឯកភាពគ្នា ជំរុញទំហំពាណិជ្ជកម្មឱ្យកើនឡើងដល់ ៦ ០០០ លានដុល្លារសហរដ្ឋអាម៉េរិក នៅក្នុងឆ្នាំ២០២០។[26]

---

[23] NCN Daily៖ ចុះផ្សាយថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៩៖ "ផ្លូវ១ ខ្សែក្រវ៉ាត់១ «ផ្លូវ សូត្រ» គឺមានប្រវត្តិតាំងពីរាជវង្សហាន កាលពីជាង ២០០០ឆ្នាំមុន" ncndailys, https://ncndailys.com/?p=4219 (accessed August 9, 2019 at 8:39pm)

[24] បណ្ឌិតសភាចារ្យ សុខ ទូច, «នយោបាយការបរទេស ម្សិលមិញ ថ្ងៃនេះ ថ្ងៃស្អែក», ទំព័រទី៤៤, បោះពុម្ពឆ្នាំ២០១៥

[25] "ឯកសារ ជំនួយស្មារតីពាក់ព័ន្ធនឹងសំណួរសម្រាប់បទសម្ភាសន៍ជាលាយលក្ខណ៍អក្សរជាមួយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាស្តីពីដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតីចិន និងទំនាក់ទំនងកម្ពុជា-ចិន" ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី

[26] ទីស្តីការគណៈរដ្ឋមន្ត្រី៖ ចុះផ្សាយថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨៖ " សុន្ទរកថារបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងពិធីជប់លៀងអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៦០ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា-ចិន" https://pressocm.gov.kh/archives/32886 (accessed July 21, 2018 at 1:10pm)។

## ៤.៥. ការគាំទ្រនយោបាយនយោបាយចិនតែមួយ

នយោបាយចិនតែមួយ គឺជានយោបាយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៧២ នាទីក្រុងស៊ាងហៃ សាធារណរដ្ឋប្រជាមានិតចិន ស្របពេលដែលមាន តំបន់ពីរ គឺចិនដីគោក និងចិនតៃវ៉ាន់ កំពុងអះអាងថា ខ្លួនជាតំណាងរដ្ឋាភិបាលស្របច្បាប់របស់ចិន។ ក្នុងគោលនយោបាយនោះក៏បានបញ្ជាក់ថា ប្រទេសទាំងឡាយដែលភ្ជាប់ទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋប្រជាមានិតចិន ត្រូវតែផ្ដាច់ទំនាក់ទំនងជាមួយសាធារណរដ្ឋចិន (Taiwan)។[27] ចំពោះកម្ពុជាគាំទ្រនយោបាយការបរទេសចិនមួយ អនុវត្តតាំងពីព្រះករុណាព្រះបិតាជាតិ សម្ដេចព្រះនរោត្តម សីហនុ។[28] នៅឆ្នាំ២០១៩ នាយករដ្ឋមន្ត្រី ហ៊ុន សែន នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសជាសាធារណៈថា នឹងមិនអនុញ្ញាតឲ្យប្រទេសចិនមកត្រួតត្រាលើខ្មែរទេ ហើយចិនក៏មិនមកត្រួតត្រាខ្មែរដែរ។ បើតាមនាយករដ្ឋមន្ត្រី នេះគឺជាគោលនយោបាយរបស់ប្រទេសចិន ដែលមិនត្រួតត្រាប្រទេសណាមួយ។[29]

## ៥.លទ្ធផលទំនាក់ទំនងរវាងប្រទេសទាំងពីរឆ្នាំ២០២០

នៅក្នុងឆ្នាំ២០២០ទំនាក់ទំនងកម្ពុជា-ចិនទទួលបានផលប្រយោជន៍ទៅវិញទៅមក គឺ **ទី១**. ទិសដៅឱ្យមានប្រសិទ្ធភាពនៃគម្រោងផ្លូវមួយនិងខ្សែក្រវ៉ាត់មួយ។ នៅចុងឆ្នាំ២០១៩ ជំនួយរបស់ចិនកសាងផ្លូវ និងស្ពាននៅកម្ពុជាមានជិត ៣ពាន់លានដុល្លារ ។ ប្រទេសចិនបានផ្ដល់សម្រាប់យកមកសាងសង់ផ្លូវ និងស្ពាន នៅកម្ពុជាមានទឹកប្រាក់សរុប **២៧៤២ ពាន់លានដុល្លារ** ក្នុងនោះមានផ្លូវ ២៧ខ្សែ ស្ពានចំនួន៨ បានសាងសង់រួច និងស្ពានមួយចំនួនផ្សេងទៀតកំពុងសាងសង។[30] **ទី២**.ចិនត្រៀមបន្ថែមឱ្យមានលំហូរហិរញ្ញវត្ថុប្រសិនបើចិនមានបញ្ហាជាមួយលោកខាងលិច។ ធនាគារសេដ្ឋកិច្ចបន្ថែមថ្មីរបស់ចិនគឺ កម្ពុជាជាផ្នែកនៃកិច្ចចរចាពាណិជ្ជកម្មសេរីជាមួយចិននៅក្នុងតំបន់អាស៊ាន។ ក្រោយចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) កម្ពុជានឹងអាចនាំចេញទំនិញ ៩៥ភាគរយ ទៅកាន់ប្រទេសចិន ដោយមិនគិតពន្ធ ក្នុងចំណោមទំនិញជាង ៣៤០មុខទំនិញ។[31] **ទី៣**. ចិនប្រជែកឥទ្ធិពលជាមួយជប៉ុនក្នុងតំប

---

[27] ជូ វិជុរក្សែបណ្ឌិតៈ ចុះផ្សាយថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥៖ "កម្ពុជា និងគោលនយោបាយចិនតែមួយៈផលចំណេញ និងការខាតបង់" ភ្នំពេញប៉ុស្តិ៍ www.postkhmer.com/វិភាគសង្គម/កម្ពុជា-និងគោលនយោបាយចិនតែមួយៈផលចំណេញ-និងការខាតបង់ (accessed February 12, 2020 at 9:09pm)

[28] សុន្ទរកថាៈ ចុះផ្សាយថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៧៖ "សេចក្ដីដកស្រង់សង្កថា ក្នុងពិធីពិសាបាយសាមគ្គី ជួបជុំ និងទទួលភារកិច្ចថ្មី សមាគមខ្មែរ-ចិន" Cnv, km.cnv.org.kh/2017/សមាគមខ្មែរ-ចិន/ (accessed January 24, 202 at 9:11pm)

[29] Grandnewsasia៖ ចុះផ្សាយថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩៖ "នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា កម្ពុជាបន្តអនុវត្តគោលនយោបាយចិនតែមួយ" https://grandnewsasia.com/detail/143799/ (accessed August 09, 2020 at 10:01pm)

[30] news.sabay ៖ ចុះផ្សាយថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ ៖ "ឆ្នាំ២០១៩ ជំនួយរបស់ចិនកសាងផ្លូវ និងស្ពាននៅកម្ពុជាមានជិត ៣ពាន់លានដុល្លារ" (https://news.sabay.com.kh/article/1191369 accessed at September 29, 2020 at 11:29am)

[31] Cpp ៖ ចុះផ្សាយថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ៖ "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ជាផ្លូវនាំឲ្យកម្ពុជាឈានទៅជាប្រទេសសិង្ហបុរីទី២" https://www.cpp.org.kh/details/225774 (accessed September 01 , 2020 at 11:11am)

ន់។ ចិនបានសម្រេចផ្តល់ជំនួយជាង ៧លានដុល្លារ ដល់កម្ពុជាលើគម្រោងចំនួន២០ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច។[32] ហើយកម្ពុជា-ចិនក៏ចុះហត្ថលេខា សម្រាប់មូលនិធិមេគង្គ-ឡានឆាង ភាគច្រើនគ្របដណ្តប់លើសកម្មភាពនានាពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចសង្គម អភិវឌ្ឍន៍ធនធានមនុស្ស សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ការកសាងសមត្ថភាព ទេសចរណ៍ និងសេវាកម្ម បរិស្ថាន និងការការពារធម្មជាតិជាដើម។ កិច្ចព្រមព្រៀងនេះមានទឹកប្រាក់ ៧ ២២៥ ៤០០ ដុល្លារ។[33] **ទី៤.** សម្លេងរបស់កម្ពុជាលើឆាកអន្តរជាតិ។ ឯកឧត្តម Wang Wentain ឯកអគ្គរដ្ឋទូតចិន ប្រចាំកម្ពុជា មានប្រសាសន៍ថា «ទោះបីជាក្នុងរយៈពេល ការរីករាលត្បាតនៃការ ចាប់ផ្តើមនៃជំងឺ រាលត្បាត កូវីដ-១៩ នេះកើតឡើងក៏ដោយទំនាក់ទំនង និងកិច្ចសហប្រតិបត្តិ ការរវាង ប្រទេសទាំងពីរ ក៏នៅតែបន្តដំណើរជាប្រក្រតី និងមានវឌ្ឍនភាពល្អប្រសើរ»។[34] **ទី៥.**ការទូតរ៉ាក់សាំងរបស់ចិនដែលអាចប្រជែងជាងមួយលោកខាងលិចបាន។

## ៦.សន្និដ្ឋាន

ទំនាក់ទំនងកម្ពុជា-ចិនមានការរីកចម្រើនជាលំដាប់ ជាពិសេសទៀតនោះមានប្រវត្តិទំនាក់ទំនងតាំងពីព.ស.២២៥មក។ កម្ពុជាមានទំនាក់ទំនងជាមួយចិនដោយបានធ្វើដំណើរត្រឹមត្រូវផ្អែកលើស្មារតីឯករាជ្យ និងផលប្រយោជនជាតិជាធំ **ទី១.** ស្របតាមសាកលភាវូនីយកម្ម ដោយចក្ខុវិស័យការកែទម្រង់ខាងក្នុង និងបង្កើតបង្កើតមិត្តនៅក្រៅប្រទេស **ទី២.** ការទទួលបានទីផ្សារដ៏ធំរបស់ចិនដែលមានប្រជាជនជិត១៤០០លាននាក់។ **ទី៣.**កម្ពុជាបានទទួលឱកាសនៃការវិនិយោគរបស់ចិន **ទី៤.**កម្ពុជាបានដើរលើវិថីត្រឹមត្រូវគឺមិនមែនចាប់យកតែចិនមួយនោះទេពោលគឺកម្ពុជាបានដើរនៅគោលនយោបាយការបរទេសចម្រុះពណ៌**ទី៥.**កម្ពុជាត្រូវត្រៀមខ្លួនក្នុងការបណ្តុះបណ្តាលក្មេងជំនាន់ក្រោយក្នុងឱកាសចិនមកវិនិយោគ **ទី៦.** ក្នុងឱកាសកម្ពុជា-ចិនមានទំនាក់ទំនងល្អកម្ពុជាបានទាក់ទាញការវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវល្បឿនលឿន ក្រោមផ្តួចផ្តើមខ្សែក្រវ៉ាត់មួយនិងផ្លូវមួយដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចកាន់តែមានសក្តានុពល **ទី៧.**កម្ពុជានៅតែជាដៃគូរដែលមានផលប្រយោជន៍សម្រាប់ចិនច្រើននៅក្នុងតំបន់និងលើកឆាកអន្តរជាតិ។

---

[32] doctor-business.asia ៖ ចុះផ្សាយថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ៖ "ចិន សម្រេចផ្តល់ជំនួយជាង ៧ លានដុល្លារ ដល់ កម្ពុជាលើគម្រោងចំនួន ២០ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច" (doctor-business.asia/ចិន-សម្រេចផ្តល់ជំនួយជាង/ accessed September 21, 2020 at 7:00pm)

[33] ភ្នំពេញប៉ុស្តិ៍ ៖ ចុះផ្សាយថ្ងៃទី២៤ មិថុនា ឆ្នាំ២០២០ ៖ "កម្ពុជា-ចិន ចុះហត្ថលេខា ២០ គម្រោង ទឹកប្រាក់ជាង $៧ លានសម្រាប់មូលនិធិមេគង្គ-ឡានឆាង" (www.postkhmer.com/ព័ត៌មានជាតិ/កម្ពុជា-ចិន-ចុះហត្ថលេខា-២០-គម្រោង-ទឹកប្រាក់ជាង-៧-លានសម្រាប់មូលនិធិមេគង្គ-ឡានឆាង accessed at September 4, 2020 at 9:00pm)

[34] ដើមអម្ពិល ៖ ចុះផ្សាយថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ ៖ "ទូតចិន ៖ ទោះជួបកូវីដ-១៩ តែទំនាក់ទំនង កម្ពុជា-ចិន នៅបន្តវឌ្ឍនភាព ល្អប្រសើរ" (accessed September 29, 2020 at11:00pm)